**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:..១២០....សសរ**

# សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលកម្ពុជា- ឡាវ- មីយ៉ាន់ម៉ា និងថៃ ស្តីពីយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ចាប់ពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៣ នៅបាហ្កាន សហភាពមីយ៉ាន់ម៉ារហូតដល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត- ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣*

**ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *ឯកសារ- កាលប្បវត្តិ*